# សេចក្តីជូនដំណឹង

## ស្តីពី

# ការបែងចែកភាគលាភ

**ធនាគារ អេស៊ីលីដា ភីអិលស៊ី** (“ធនាគារ អេស៊ីលីដា”) មានកិត្តិយស សូមជម្រាបជូនដំណឹងដល់ភាគហ៊ុនិកទាំងអស់ មេត្តាជ្រាបថា ដោយអនុលោមតាមសេចក្តីសម្រេច នៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៥ របស់ធនាគារ អេស៊ីលីដា នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥ លិខិតលេខ ១៣៧១/២៥ ន.ម.ក. ចុះថ្ងៃចន្ទ ១រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២៥ របស់និយ័តករមូលបត្រកម្ពុជា ស្តីពីការបែងចែកភាគលាភសម្រាប់ឆ្នាំ២០២៤ និងលិខិតលេខ ធ១៧-០២៥-១២៣១ ឆ.ត ចុះថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥ របស់ធនាគារជាតិ នៃ កម្ពុជា ធនាគារ អេស៊ីលីដា សម្រេចបែងចែកភាគលាភសម្រាប់ប្រាក់ចំណេញឆ្នាំ២០២៤ ជូនភាគហ៊ុនិក ដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ប្រភេទភាគលាភដែលត្រូវបែងចែក | : **សាច់ប្រាក់** |
| ២. | រយៈពេល នៃភាគលាភ | : **ប្រចាំឆ្នាំ** |
| ៣. | អនុបាត នៃការបែងចែកភាគលាភ | : **២០%** |
| ៤. | ភាគលាភសរុបដែលត្រូវបែងចែក | : **៩៨.៦៧៦.៦៥៨.២២៦,៩៩រៀល** |
| ៥. | ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ | : **២២៧,៨០៤៩ រៀល** |
| ៦. | កាលបរិច្ឆេទអិចឌីវីដឺនដ៍ | : **ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥** |
| ៧. | កាលបរិច្ឆេទប្រកាសបញ្ជីឈ្មោះភាគហ៊ុនិកដែលត្រូវទទួលភាគលាភ (កាលបរិច្ឆេទកំណត់ទុកនៃការបែងចែកភាគលាភ) | : **ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥** |
| ៨. | កាលបរិច្ឆេទទូទាត់ភាគលាភ | : **ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥** |

**បញ្ជាក់៖**

- ភាគហ៊ុនិកដែលមានសិទ្ធិទទួលបានភាគលាភដូចការកំណត់ខាងលើ គឺជាភាគហ៊ុនិកដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះភាគហ៊ុនិក (Record Date) នៅ**ថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥**។
- ភាគហ៊ុនិកដែល**លក់**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥ គឺនៅតែមានសិទ្ធិ**ទទួលបានភាគលាភនេះដដែល។
- ភាគហ៊ុនិកដែល**ទិញ**មូលបត្រកម្មសិទ្ធិ (ភាគហ៊ុន) របស់ខ្លួននៅ**ថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២៥ គឺមិនមានសិទ្ធិ**ទទួលបានភាគលាភនេះទេ។
- ការទូទាត់ភាគលាភនឹងចាប់ផ្តើមពី**ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥ ដល់ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥** នៅរៀងរាល់ថ្ងៃធ្វើការ។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Building Nº 61, Preah Monivong Blvd., Sangkat Srah Chak, Khan Doun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: +855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកផ្នែកប្រតិបត្តិការបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់ (**ភ្នាក់ងារ RTP**) ដូចខាងក្រោម៖

- **លោក ហួត សុភី**
  - ទូរស័ព្ទ: (៨៥៥) ១៥ ៩០០ ៥៣៨
  - អ៊ីម៉ែល: huot.sophy@acledabank.com.kh
- **លោកស្រី សំរិទ្ធ វណ្ណីបុប្ផារដ្ឋ**
  - ទូរស័ព្ទ: (៨៥៥) ៧០ ៥០០ ៣៧៧
  - អ៊ីម៉ែល: samreth.vannybopharath@acledabank.com.kh
- **កញ្ញា ចាន់ ទេពកញ្ញា**
  - ទូរស័ព្ទ: (៨៥៥) ១៦ ២៩៥ ៤៣២
  - អ៊ីម៉ែល: op.rtp@acledabank.com.kh
- **លោក កែន រិទ្ធពុទ្ធា**
  - ទូរស័ព្ទ: (៨៥៥) ១៥ ៨០០ ៦៦៣
  - អ៊ីម៉ែល: ken.rithputhea@acledabank.com.kh

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាជ្រាបជាព័ត៌មាន៕

ថ្ងៃព្រហស្បតិ៍ ២រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៥
**ធនាគារ អេស៊ីលីដា ភីអិលស៊ី**